# សុន្ទរកថាស្វាគមន៍ និងថ្លែងអំណរគុណ
# ឯកឧត្តម ម៉ៅ ហាវណ្ណាល់
# រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
# ថ្លែងក្នុងឱកាសសន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិលឆ្នាំ២០១៣-២០១៧
# និងលើកទិសដៅសម្រាប់ឆ្នាំ២០១៨-២០២៣

ថ្ងៃព្រហស្បតិ៍ ០៩កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៨

៣៣✻៣៣

- *សូមគោរព **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាទីគោរព!*
- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរាជរដ្ឋាភិបាលកម្ពុជា ជាទីរាប់អាន!*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងស្ថាប័នពាក់ព័ន្ធ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ជាទីមេត្រី!*

១. ថ្ងៃនេះ តាងនាមឲ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមគោរពស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីបើក « សន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិលឆ្នាំ ២០១៣-២០១៧ និងលើកទិសដៅអនុវត្តសម្រាប់ឆ្នាំ ២០១៨-២០២៣ » របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នាពេលនេះ។

២. ជាមួយគ្នានេះដែរ ជំនួសមុខឲ្យគណៈកម្មការរៀបចំសន្និបាត ខ្ញុំបាទសូមស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងក្រសួងស្ថាប័នចំណុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានឆ្លៀតឱកាសដ៏មមារញឹក អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបើកសន្និបាតនេះ ដែលញុំាងឲ្យអង្គពិធីទាំងមូលប្រព្រឹត្តទៅប្រកបដោយភាពអធឹកអធមក្រៃលែង។

*- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!*

៣. ក្នុងបណ្តាឆ្នាំកន្លងមក រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំធ្វើការបូកសរុបវាយតម្លៃលទ្ធផលការងាររបស់ខ្លួនជាលក្ខណៈផ្ទៃក្នុង ជារៀងរាល់ឆ្នាំ។ ដោយឡែក សន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិលនៅឆ្នាំនេះ គឺមិនត្រឹមតែជាការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៧ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការពិនិត្យវាយតម្លៃវឌ្ឍនភាពការងារសម្រាប់រយៈពេល ៤ឆ្នាំ ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រេចបានតាំងពីដើមអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។

៤. តាមរយៈសន្និបាតឆ្នាំនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនឹងដាក់ចេញនូវយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារអាទិភាព សម្រាប់ឲ្យគ្រប់អង្គភាពក្រោមឱវាទ បន្តអនុវត្ត ដើម្បីសម្រេចបាននូវទស្សនៈវិស័យដែលបានដាក់ចេញគឺ «អភិវឌ្ឍន៍ប្រព័ន្ធអាកាសចរស៊ីវិលដែលមានសុវត្ថិភាព សន្តិសុខ ល្អប្រសើរ និងប្រសិទ្ធភាពខ្ពស់ ដើម្បីធ្វើជាកត្តាលីករដ៏សំខាន់សម្រាប់ការរីកលូតលាស់នៃសេដ្ឋកិច្ច និងសេវាកម្មរបស់ប្រទេសជាតិ ដោយរួមជាមួយនឹងគោលបំណងលើកកំពស់កិច្ចសហប្រតិបត្តិការ និងការប្រកួតប្រជែងនៅក្នុងវិស័យអាកាសចរស៊ីវិលនេះ»។

៥. ក្នុងឱកាសនេះផងដែរ ខ្ញុំបាទសូមគោរពជម្រាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ និងអង្គសន្និបាតទាំងមូលមេត្តាជ្រាបថា វិស័យអាកាសចរណ៍ជាឧស្សាហកម្មដែលកំពុងតែរីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងពិភពលោក និងតំបន់ ដែលត្រូវបានគេចាត់ទុកថា ជាកត្តាយុទ្ធសាស្ត្រនៃផលិតកម្ម និងជាស្នូលនៃដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ ដោយសារតែតួនាទីទ្វេគុណរបស់ខ្លួនគឺៈ ទី១.ជាសេវាកម្មពាណិជ្ជកម្ម និងទី ២.ជាយានសម្រាប់កិច្ចការពាណិជ្ជកម្មនៅក្នុងវិស័យសេវាកម្មផ្សេងៗទៀត។ វិស័យដឹកជញ្ជូនផ្លូវអាកាសដែលមានប្រសិទ្ធភាព មិនត្រឹមតែជួយសម្រួលដល់ការដឹកជញ្ជូនអ្នកធ្វើដំណើរ និងទំនិញក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះទេ ប៉ុន្តែវិស័យនេះក៏បានជួយដោយផ្ទាល់ដល់ការបង្កើនសកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ បង្កើនចំណូលជាតិ និងលើកកម្ពស់ទំនាក់ទំនងសង្គម និងផ្តល់នូវផលប្រយោជន៍ផ្សេងៗទៀត សម្រាប់ប្រទេសជាតិផងដែរ។

៦. ដោយយល់ច្បាស់នូវតួនាទីនិងសារៈសំខាន់នៃវិស័យអាកាសចរស៊ីវិលនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយបើកចំហដើងមេឃ ដែលជាលទ្ធផល បានធ្វើឲ្យវិស័យអាកាសចរស៊ីវិលកម្ពុជាមានការរីកចម្រើនទៅមុខយ៉ាងខ្លាំងស្ថិតក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ និងកំពុងប្រែក្លាយព្រះរាជាណាចក្រកម្ពុជាជាមជ្ឈមណ្ឌលអាកាសចរណ៍ និងទេសចរណ៍មួយ ដែលមានភាពទាក់ទាញ ក្នុងតំបន់ និងពិភពលោក។

- *ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!*

៧. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឲ្យដឹកនាំ និងអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល(ដឹកជញ្ជូនផ្លូវអាកាស)នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាបាននូវការផ្តល់សេវាកម្មដឹកជញ្ជូនផ្លូវអាកាស ប្រកបដោយសុវត្ថិភាព សន្តិសុខ ប្រសិទ្ធភាព គុណភាព ព្រមទាំងប្រសិទ្ធភាពចំណាយសម្រាប់ជាតិ ទាំងការហោះហើរជាលក្ខណៈអន្តរជាតិ និងក្នុងស្រុក នៅកម្រិតស្តង់ដាអន្តរជាតិ ដែលជាកត្តារួមចំណែកដ៏សំខាន់របស់វិស័យនេះ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម របស់ព្រះរាជាណាចក្រកម្ពុជា។

៨. ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងឆ្លើយតបទៅនឹងបេសកកម្មរបស់ខ្លួន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានកំណត់ និងបានដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រជាអាទិភាពសម្រាប់ជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ លើវិស័យអាកាសចរស៊ីវិល ដូចខាងក្រោម៖

**ក. ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យអាកាសចរណ៍ស៊ីវិល៖**

- ធ្វើសមាហរណកម្ម និងធ្វើឱ្យមានសុខដុមនីយកម្មបន្តិចម្តងៗ ជាមួយនឹងគោលនយោបាយបើកចំហជើងមេឃរបស់ អាស៊ាន/មហាអនុតំបន់ទន្លេមេគង្គ និងក្រុមប្រទេសកម្ពុជា ឡាវ ភូមា វៀតណាម(CLMV) និងកិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងៗទៀត។
- ជំរុញការកសាង និងកែលម្អសមត្ថភាពស្ថាប័ន ជាពិសេស កែសម្រួលរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដើម្បីប្រែក្លាយជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ ទៅជាបែបវិមជ្ឈការ និងសហវិមជ្ឈការ ក៏ដូចជាដើម្បីឱ្យស្របតាមតម្រូវការអង្គការអាកាសចរស៊ីវិលអន្តរជាតិ។

**ខ. ការពង្រឹងសន្តិសុខ និងសុវត្ថិភាពហោះហើរ៖**

- ចងក្រងបទប្បញ្ញត្តិអាកាសចរស៊ីវិលបន្ថែម ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ក្នុងការពង្រឹងសន្តិសុខ សុវត្ថិភាព ក្នុងការហោះហើរ និងទប់ស្កាត់ការប្រែប្រួលធាតុអាកាស ដែលត្រូវបង្កឡើងដោយសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។
- ពង្រឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដោយរៀបចំនូវបច្ចុប្បន្នកម្ម និងបទប្បញ្ញត្តិនានា សម្រាប់បទដ្ឋានបច្ចេកទេស បទដ្ឋានសេដ្ឋកិច្ច និងចីរភាពបរិស្ថាន ក្នុងវិស័យអាកាសចរស៊ីវិល។

. លើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ សន្តិសុខ សុវត្ថិភាព និងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថានក្នុងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ដោយផ្អែកលើគោលការណ៍ច្បាប់ បទប្បញ្ញត្តិ និងវិធាននានា។
. បង្កើតកិច្ចព្រមព្រៀងផ្លូវការនានា ជាមួយប្រទេសជិតខាងសម្រាប់ការងារសន្តិសុខ សុវត្ថិភាព និងការផ្លាស់ប្តូរទិន្នន័យប្រតិបត្តិការ។

**គ. ការពង្រឹងសេវាកម្មនាំផ្លូវអាកាស និងអាកាសយានដ្ឋានៈ**

. កែលម្អ និងធ្វើទំនើបកម្ម នូវអាកាសយានដ្ឋានដែលបានកំណត់ និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធរួមមានៈ ការអនុវត្តនូវប្រព័ន្ធថ្មីមួយ គឺប្រព័ន្ធគមនាគមន៍នាំផ្លូវ ការឃ្លាំមើលការហោះហើរនិងការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាសថ្មី(New CNS/ATM)តាមផ្កាយរណប។
. ជំរុញការចូលរួមពីវិស័យឯកជន និងសាធារណៈនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងសេវាកម្មអាកាសចរណ៍ ជាពិសេសជំរុញឱ្យមានការវិនិយោគពីវិស័យឯកជនទៅលើសកម្មភាព ដែលបម្រើឱ្យវិស័យអាកាសចរណ៍ដោយផ្ទាល់ និងប្រយោល។ សកម្មភាពទាំងនោះ រួមមានៈ អគារលក់ដូរ ទីលានវាយកូនហ្គោល ឧទ្យានសម្រាប់កំសាន្តកីឡាអាកាសចរណ៍ជាដើម ដែលមានទីតាំងនៅក្បែរអាកាសយានដ្ឋាន ដែលនឹងត្រូវបានជំរុញដើម្បីបង្កើនចំណូល និងធានាចីរភាពរបស់អាកាសយានដ្ឋាន និងដើម្បីលើកកម្ពស់វិស័យទេសចរណ៍។
. លើកកម្ពស់ការចូលរួមក្នុងការត្រួតពិនិត្យ និងសម្របសម្រួលដំណើរនៃការអភិវឌ្ឍធុរកិច្ចទាំងឡាយ ដែលស្ថិតនៅក្រោមកិច្ចសន្យាសម្បទាន ។
. បន្តជំរុញការលើកកម្ពស់សមត្ថភាព និងការយល់ដឹងរបស់និយោជិតស្ត្រី ដើម្បីធ្វើឱ្យប្រសើរឡើងនូវតួនាទី ស្ថានភាពស្ត្រី នៅក្នុងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។
. អភិវឌ្ឍព័ត៌មានវិទ្យា ព័ត៌មានឧតុនិយម ប្រព័ន្ធទិន្នន័យស្ថិតិ និងធ្វើការសិក្សាអង្កេត។

៩. ជាលទ្ធផលវឌ្ឍនភាពនៃការអនុវត្តការងាររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលពីឆ្នាំ ២០១៣ រហូតដល់ឆ្នាំ២០១៧ រួមមានៈ

**ក. សម្រាប់ការងារចូលរួមក្នុងវិស័យសេដ្ឋកិច្ចកម្ពុជាៈ**

- បានបង្កើតការងារដោយផ្ទាល់ និងដោយប្រយោល ចំនួន ១,៧លានការងារស្មើនឹង ២០% នៃចំនួនប្រជាជនធ្វើការសរុបរបស់ប្រទេសកម្ពុជា។
- បានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចដោយផ្ទាល់ និងដោយប្រយោល ប្រមាណជា ២,៧ ពាន់លាន ដុល្លាស្មើនឹង ១៧% នៃ ផសស ( 17% of Cambodia total GDP )។

- បានគាំទ្រ និងជម្រុញឲ្យមានកំណើនដល់វិស័យទេសចរណ៍ និងពាណិជ្ជកម្ម ទាក់ទាញ និងជម្រុញដល់ការវិនិយោគផ្ទាល់ពីបរទេស (FDI) និងធុរកិច្ចក្នុងស្រុក។
- បានធ្វើឲ្យមានការតភ្ជាប់រវាងប្រជាជននិងប្រជាជន ប្រទេសនិងប្រទេស វប្បធម៌ និងវប្បធម៌ ផ្តល់នូវមាត់ច្រកទៅកាន់ទីផ្សារ ការផ្សារភ្ជាប់ ឬធ្វើឱ្យកាន់តែជិតឡើងរវាងប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសអភិវឌ្ឍន៍រួច។

**ខ. សម្រាប់ការងារ ICAO និងការកសាងបទប្បញ្ញត្តិ វិស័យអាកាសចរស៊ីវិលៈ**

- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានធ្វើបច្ចុប្បន្នភាព និងប្រកាសឱ្យប្រើប្រាស់នូវបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា (Cambodia Civil Aviation Regulation-CCAR) ចំនួន២១ ដែលទាក់ទងដល់ការបញ្ញត្តិស្តីពីលទ្ធភាពហោះហើរ (AIR) ប្រតិបត្តិការហោះហើរ (OPS) ការផ្តល់វិញ្ញាបនបត្រ(PEL) ការនាំផ្លូវអាកាស (ANS) អាកាសយានដ្ឋាន (AGA) និងការស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ (AIG)។
- បានធ្វើបច្ចុប្បន្នភាព និងប្រកាសឱ្យប្រើប្រាស់នូវនីតិវិធី និងឯកសារណែនាំនានា ដើម្បីអនុវត្តបទប្បញ្ញត្តិអាកាសចរស៊ីវិលស្របតាមស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។
- បាននឹងកំពុងរៀបចំស្វែងរកជំនួយបច្ចេកទេសក្នុងការរៀបចំ បទប្បញ្ញត្តិផ្នែកសេដ្ឋកិច្ចអាកាសចរស៊ីវិល និងបទប្បញ្ញត្តិបច្ចេកទេសមួយចំនួនបន្ថែមទៀត ដើម្បីធានាឱ្យបាននូវបរិការណ៍ធុរកិច្ច ក្នុងវិស័យដឹកជញ្ជូនផ្លូវអាកាសប្រកបដោយសមធម៌ និងតម្លាភាព។
- បានរៀបចំកម្មវិធីសន្តិសុខអាកាសចរជាតិ (National Security Program) កម្មវិធីសុវត្ថិភាពជាតិ (SSP-State Safety Program) កម្មវិធីសុវត្ថិភាពនាំផ្លូវអាកាស កម្មវិធីត្រួតពិនិត្យសុវត្ថិភាព។
- បានទទួលការចុះធ្វើសវនកម្មរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) ផ្នែកសន្តិសុខ (USAP) និងសុវត្ថិភាព (USOAP) ដោយជោគជ័យ ។
- បានរៀបចំ និងអនុវត្តផែនការកែតម្រូវលើចំណុចខ្វះខាតដែលអង្គការ ICAO បានរកឃើញជាបណ្តើៗ ។

**គ. សម្រាប់ការងារកិច្ចសហប្រតិបត្តិការ និងការដឹកជញ្ជូនតាមផ្លូវអាកាសៈ**

- បន្តការចរចារបើកផ្លូវហោះហើរថ្មីៗទៀត (Air Service Agreement) ជាមួយប្រទេសជាដៃគូនៅក្នុងតំបន់ និងនៅក្នុងពិភពលោក

- មានក្រុមហ៊ុនអាកាសចរណ៍ឯកជនក្នុងស្រុកចំនួន ១០ កំពុងប្រតិបត្តិការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញចេញ-ចូលលើដំណាក់ផ្លូវហោះហើរក្នុងស្រុក និងអន្តរជាតិ មានដូចជាៈ
  - ១.ក្រុមហ៊ុនខាមបូឌាអង្គរអ៊ែរ
  - ២.ក្រុមហ៊ុន ស្កាយអង្គរ អ៊ែរឡាញ
  - ៣.ក្រុមហ៊ុន ខេមបូឌា បាយ័ន អ៊ែរឡាញ
  - ៤.ក្រុមហ៊ុន បាសសាកា អ៊ែរ
  - ៥.ក្រុមហ៊ុន ជេស៊ី ខាមបូឌារ អ៊ិនធើណេសសិនណល អ៊ែរឡាញ
  - ៦.ក្រុមហ៊ុន ឡានមុី អ៊ែរឡាញ
  - ៧.ក្រុមហ៊ុន ស្មូលផ្លែនណេត និងមានក្រុមហ៊ុនឧទ្ធម្ភាគចក្រចំនួនបីគឺ
  - ៨.ក្រុមហ៊ុន ហេលិខបធឺរ ខេម បូឌា
  - ៩.ក្រុមហ៊ុន ហេលិស្តារ ខេមបូឌា។
  - ១០.ក្រុមហ៊ុនញូញៀនឌិវេលឡុបមិនគ្រុប (Union Development Group)
- ក្រុមហ៊ុនអាកាសចរណ៍មួយចំនួនទៀតបាន និងកំពុងស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការហោះហើរ (AOC) ពីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីដំណើរការហោះហើរដឹកជញ្ជូនអ្នកដំណើរនិងទំនិញក្នុងស្រុក និងក្រៅស្រុក។
- មានក្រុមហ៊ុនអាកាសចរណ៍បរទេសចំនួន៤០ បាននិងកំពុងប្រតិបត្តិការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាលក្ខណៈអន្តរជាតិ មកកាន់ព្រះរាជាណាចក្រកម្ពុជា
- កំណើនអ្នកដំណើរបានកើនដល់ចំនួន ៨លាននាក់(ចេញ-ចូល) នៅអាកាសយានដ្ឋានអន្តរជាតិទាំងបីរបស់ប្រទេសកម្ពុជា
- កំណើនការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស បានឈានដល់ចំនួន ៦០ពាន់តោន (នៅអាកាសយានដ្ឋានអន្តរជាតិទាំងបី) ។
- ចំនួនជើងហោះហើរ (Flight Movement)៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មានចំនួនជាមធ្យម ៥៥ជើង ក្នុងមួយថ្ងៃ ឬ ១៦៥០ជើងក្នុងមួយខែ។ នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប មានចំនួនជាមធ្យម ៥៧ជើង ក្នុងមួយថ្ងៃ ឬ១,៧១០ជើង ក្នុង០១ខែ និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ មានចំនួនជាមធ្យម ៨ជើង ក្នុងមួយថ្ងៃ ឬ២៤០ជើង ក្នុងមួយខែ។
- ការហោះហើរឆ្លងកាត់ដែនអាកាសកម្ពុជា (Over flight) មានចំនួនជាមធ្យម ១៥៣ជើង ក្នុងមួយថ្ងៃ ឬ ៤,៥៨៥ជើងក្នុងមួយខែ។

**ឃ. សម្រាប់ការងារហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន៖**

- អាកាសយានដ្ឋានអន្តរជាតិទាំង៣ត្រូវបានធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានទាំងរូបភាព និងសមត្ថភាព ដោយមានការពង្រីកស្ថានីយ៍អ្នកដំណើរ ចំណតអាកាសយាន (អាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានចំនួន៦ចំណត និងចំណតអាកាសយានដ្ឋានអន្តរជាតិសៀមរាបបានចំនួន៥ចំណត)
- បានពង្រីកទំហំផ្លូវរត់ និងពង្រឹងតំបន់សុវត្ថិភាពចុងផ្លូវរត់០៥ (អាកាសយានដ្ឋានអន្តរជាតិសៀមរាប) បានបំពាក់ឧបករណ៍លើដីថ្មី បំពាក់ឧបករណ៍ស្ថានីយ៍អ្នកដំណើរថ្មីៗ និងទំនិញ ព្រមទាំងបានបណ្តុះបណ្តាលបុគ្គលិកសម្រាប់ស្ថានីយ៍អ្នកដំណើរក្នុង និងក្រៅប្រទេសនៅអាកាសយានដ្ឋានអន្តរជាតិទាំង៣
- ការអភិវឌ្ឍអាកាសយានដ្ឋានអន្តជាតិថ្មី នៅខេត្តសៀមរាប និងនៅខេត្តកោះកុង (តារាសាគរ) តាមរយៈការចូលរួមភាពជាដៃគូ រវាងរដ្ឋ និងឯកជន (PPP)
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានក្នុងស្រុកដោយប្រើប្រាស់ថវិកាជាតិ ដែលបានវិភាជផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលដៅបម្រើសេវាកម្មអាកាសចរណ៍ជូនដល់ក្រុមហ៊ុន និងអង្គការអន្តរជាតិនានា។ ដោយឡែកអាកាសយានដ្ឋានខេត្តកោះកុងត្រូវបាន រាជរដ្ឋាភិបាលបានផ្តល់សម្បទានឱ្យក្រុមហ៊ុនឯកជនធ្វើការវិនិយោគ ដើម្បីបម្រើវិស័យទេសចរណ៍នៅតំបន់អេកូទេសចរណ៍នោះ។ ចំណែកឯអាកាសយានដ្ឋានមណ្ឌលគិរី អាកាសយានដ្ឋានរតនគិរី អាកាសយានដ្ឋានខេត្តព្រះវិហារ និងអាកាសយានដ្ឋានក្រចេះ រាជរដ្ឋាភិបាលបានប្រគល់ជូនអាជ្ញាធរខេត្តជាអ្នកគ្រប់គ្រងក្នុងឆ្នាំ២០១៦។ តាមរយៈគម្រោងវិនិយោគសាធារណៈបីឆ្នាំរំកិល រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំ និងដាក់ស្នើសុំគម្រោងអាទិភាពជូនរាជរដ្ឋាភិបាលជារៀងរាល់ឆ្នាំ ក្នុងនោះមានដូចជា គម្រោងការស្តារ និងកែលម្អអាកាសយានដ្ឋានខេត្តស្ទឹងត្រែង និងអាកាសយានដ្ឋានខេត្តបាត់ដំបង ។

**ង. សម្រាប់ការងារពង្រឹងសុវត្ថិភាពនាំផ្លូវអាកាស៖**

- តាមរយៈគម្រោងការពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីមានសមត្ថភាពឈានទៅអនុវត្តប្រព័ន្ធនាំផ្លូវអាកាសថ្មីតាមផ្កាយរណប (New CNS/ATM System) ដែលជាគម្រោងជំនួយបច្ចេកទេសរបស់រាជរដ្ឋាភិបាលជប៉ុន ត្រូវបានបញ្ចប់ជាស្ថាពរនៅឆ្នាំ២០១៥ ប្រទេសកម្ពុជាបានអនុវត្តបទដ្ឋានហោះហើរថ្មី ដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណប(PBN) នៅអាកាសយានដ្ឋានអន្តរជាតិទាំង៣ រួមមាន៖ អាកាសយានដ្ឋានអន្តរ

ជាតិភ្នំពេញ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ អាកាសយានដ្ឋានអន្តរជាតិសៀមរាប នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៦។ ការអនុវត្តប្រព័ន្ធនាំផ្លូវអាកាសថ្មី បាននិងកំពុងចូលរួមកាត់បន្ថយបាននូវ ពេលវេលា រយៈចំងាយ និងបង្កើនប្រសិទ្ធភាពដល់ប្រតិបត្តិការហោះហើរ ដែលធ្វើឱ្យមានថ្លៃដើមទាប និងបង្កើនបាននូវសមត្ថភាព និងគុណភាព ក្នុងការប្រកួតប្រជែងខ្ពស់ជាងមុន។

- ការធ្វើទំនើបកម្ម ប្រព័ន្ធនាំផ្លូវអាកាសពី ប្រព័ន្ធ AIS ទៅប្រព័ន្ធ AIM ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពប្រតិបត្តិការគ្រប់គ្រងចរាចរណ៍ដែនអាកាសកម្ពុជា។

**ច. សម្រាប់ការងារអភិវឌ្ឍន៍ធនធានមនុស្ស៖**

- ការពង្រឹងស្ថាប័ន និងធនធានមនុស្ស (បណ្តុះបណ្តាលក្នុងស្រុក CATC នឹងបណ្តុះបណ្តាលក្រៅស្រុក)
- តាមរយៈកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងសាធារណរដ្ឋកូរ៉េ និងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានទទួលជំនួយឥតសំណងសម្រាប់គម្រោងការសាងសង់មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលនៅកម្ពុជាមានទឹកប្រាក់ចំនួន១០,១០ លានដុល្លាររយៈពេលអនុវត្ត៤ឆ្នាំ ចាប់អនុវត្តពីឆ្នាំ២០១៤-២០១៧ ដែលនៅក្នុងសមាសភាគរបស់គម្រោងរួមមាន៖ ការសាងសង់អគារមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ការបំពាក់ឧបករណ៍សម្ភារបរិក្ខារបច្ចេកទេស បម្រើឲ្យការបណ្តុះបណ្តាល ការរៀបចំផែនការមេសម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស ការបញ្ជូនអ្នកជំនាញការកូរ៉េមកកម្ពុជា និងការបញ្ជូនមន្ត្រីកម្ពុជាទៅទទួលការបណ្តុះបណ្តាលនៅកូរ៉េ ដើម្បីក្លាយជាគ្រូបង្គោលនាពេលអនាគត ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យអាកាសចរស៊ីវិល ឱ្យមានសមត្ថភាពប្រកួតប្រជែងខ្ពស់ និងលើកកំពស់គុណភាព និងប្រសិទ្ធភាពការងារ ធានាបាននូវសន្តិសុខ និងសុវត្ថិភាពខ្ពស់ សម្រាប់ការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ស្របតាមស្តង់ដា និងអនុសាសន៍របស់អង្គការ អាកាសចរស៊ីវិលអន្តរជាតិ។

**១០.** សមិទ្ធផលទាំងនេះ គឺបានមកពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងភាពជាម្ចាស់លើកិច្ចការដ៏មានសារៈសំខាន់នេះ។ សមិទ្ធផលទាំងនេះពិតជាមិនអាចសម្រេចបានដោយមិនមានការចូលរួម និងកិច្ចសហការពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀតនោះឡើយ។

*- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!*

**១១.** មុននឹងបញ្ចប់ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការធ្វើឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតនៅក្នុងវិស័យអាកាសចរស៊ីវិល នាពេលកន្លងមកនេះ។

**១២.** ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមប្រកបដោយសុខភាពល្អ សុភមង្គលគ្រប់ក្រុមគ្រួសារ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជូនជាតិ មាតុភូមិ និងប្រជាជន។

**១៣.** ខ្ញុំបាទសូមគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាថ្លែងសុន្ទរកថាគន្លឹះបើក « សន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិលឆ្នាំ ២០១៣-២០១៧ និងលើកទិសដៅអនុវត្តសម្រាប់ឆ្នាំ ២០១៨-២០២៣ » ដោយក្តីអនុគ្រោះ។

**សូមអរគុណ!**